# អរិយធម៌ឥណ្ឌូស

ឥណ្ឌូស គឺជាអរិយធម៌ចំណាស់មួយក្នុងចំណោមបណ្តាអរិយធម៌ដំបូងៗទាំងបីលើពិភពលោកដែលក្នុងនោះមានដូចជា មេសូប៉ូតាមី អេហ្ស៊ីប និងឥណ្ឌូស ។ អរិយធម៌នេះមានការរីកចម្រើនចាប់ពីឆ្នាំ ២៦០០ ដល់ ១៩០០ ឆ្នាំ មុនគ.ស.នៅតំបន់អាស៊ីខាងត្បូង។[១]

អរិយធម៌នេះមានការរីកចម្រើនខ្លាំងនៅតាមតំបន់ចន្លោះទន្លេពីរ គឺទន្លេឥណ្ឌូស និងទន្លេ Ghaggar-Hakra ដែលសព្វថ្ងៃស្ថិតនៅចន្លោះប្រទេសប៉ាគីស្ថាន និងប្រទេសឥណ្ឌា (រូបលេខ១)។ ហើយអរិយធម៌នេះក៏ជាដើមកំណើតរបស់អរិយធម៌ឥណ្ឌាផងដែរ។[២] គួរបញ្ជាក់ដែរថាការជ្រើសរើសតាំងទីនៅតាមតំបន់ទន្លេនេះ គឺមិនមែនចៃដន្យនោះទេ គឺស្របទៅតាមវិស័យកសិកម្ម នេសាទ និងការចិញ្ចឹមសត្វដែលមនុស្ស ពឹងផ្អែកទៅលើប្រភពទឹកជាសំខាន់ ។

មនុស្សក្នុងអរិយធម៌ឥណ្ឌូសមានការលូតលាស់ខ្លាំងលើការរៀបចំក្រុង ដែលតាមរយៈការកំណាយបុរាណវិទ្យានៅឆ្នាំដើមទសវត្សទី៩០ ដោយអ្នកស្រាវជ្រាវអង់គ្លេសបានរកឃើញទីតាំងក្រុងបុរាណចំនួនពីរកន្លែងផ្សេងគ្នាមួយហៅថា Harappa និងមួយទៀតមានហៅថា Mohenjo-Daro ដែលមានន័យថាភ្នំនៃសេចក្តីស្លាប់ (Hill of Dead) ។[៣] ទិន្នន័យនៃការកំណាយនៅទីតាំងទាំងពីរនោះ ត្រូវបានអ្នកស្រាវជ្រាវចាត់ទុកថា ជាទីក្រុងចំណាស់ជាងគេនៅក្នុងតំបន់អាស៊ីខាងត្បូងនេះ ដែលទីក្រុងទាំងពីរនោះប្រហែលជាកកើតនៅប្រមាណ 2000ជាងឆ្នាំ មុនគ.ស. (រូបលេខ២-៣)។[៤] ហើយការធ្វើកំណាយបុរាណវិទ្យានេះក៏បានបង្ហាញឱ្យឃើញពីរចនាសម្ព័ន្ធនៃការរៀបចំទីក្រុង Harappa និង Mohenjo-daro ដោយទីក្រុងទាំងពីរនេះមានកំពែងដីលើកព័ទ្ធជុំវិញ មានសំណង់សាធារណៈដូចជាអណ្តូងទឹក

[១] www.dailymail.co.uk: Indus Valley civilization

[២] Brisset Isabelle 2014, p4

[៣] https://www.britannica.com: Mahejo-daro

[៤] Brisset Isabelle 2014, p. 17

អាងទឹក ប្រព័ន្ធបង្ហូរទឹកផ្ទះប្រជាជន និងមានផ្លូវស្របតាមអក្សរប្រណ្ដោយថ្ងៃ ទទឹងថ្ងៃ (រូបលេខ ៤-៥)។ មនុស្សក្នុងសម័យអរិយធម៌នេះត្រូវបានគេកត់សម្គាល់ថា មានបច្ចេកទេសខ្ពស់ និងនយោបាយពាក់ព័ន្ធនឹងការរៀបចំដំណើរការកសាងទីក្រុងបុរាណ Harappa និង Mohenjo-daro ដែលមានប្រព័ន្ធជាពសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ គួរបញ្ជាក់ដែរថា មុននៃការរកឃើញ Harappa និង Mohenjo-daro ទីក្រុងទាំងពីរនេះ គឺកប់នៅក្រោមដីជ្រៅ ទើបនៅឆ្នាំ ១៩២១ និង ១៩២២ អ្នកស្រាវជ្រាវបានកំណាយសង្គ្រោះឡើងវិញ ។ ការរកឃើញទីក្រុង Mohenjo-daro គឺនៅឆ្នាំ ១៩២២ គេបានកំណាយលើទីតាំងចេតិយចាស់មួយដែលបានកសាងនៅលើកំពែងក្រុងនេះ ដែលចេតិយនោះប្រហែលកសាងនៅដើមមុនស.វ.ទី២នៃគ.ស.។[៥]

ចំពោះការគោរពប្រតិបត្តិសាសនា និងអក្សរវិញ យើងពុំបានដឹងច្បាស់លាស់នោះទេ គ្រាន់តែតាមរយៈការរកត្រាដែលមានអក្សរ និងមានរូបសត្វផ្សេងៗ ដែលអ្នកស្រាវជ្រាវគិតទំនងជា អានពីស្ដាំទៅឆ្វេង ដែលដូចនឹងភាសាក្នុងអម្បូរ ឥណ្ឌូ-អឺរ៉ុប និងឥណ្ឌាខាងត្បូង (រូបលេខ៦)។[៦] តាមរយៈរូបចម្លាក់ល្បីៗមួយចំនួនដូចជា រូបចម្លាក់ស្ត្រីមានផ្ទៃពោះ រូបសត្វដែលបានរកឃើញនៅ Harappa និង Mohenjo-daro អ្នកស្រាវជ្រាវអាចគិតថា មនុស្សនៃអរិយធម៌នេះក៏មិនខុសអ្វីពីអរិយធម៌មេសូប៉ូតាមីដែរ ពោលការគោរពអទិទេពនៃការបង្កកំណើត(រូបលេខ៧)។ ផ្ទុយពីអរិយធម៌ មេសូប៉ូតាមី និងអេហ្ស៊ីប អរិយធម៌ឥណ្ឌូស ហាក់បីដូចជាពុំសូវឃើញមានសំណង់ប្រាសាទ ឬសំណង់សាសនាផ្សេងៗដែលជាកស្តុតាងជាក់លាក់ក្នុងការបង្ហាញអំពីការគោរពប្រតិបត្តិ។

មនុស្សក្នុងអរិយធម៌នេះ មានជំនាញក្នុងការផលិតវត្ថុសិល្បៈ តាមទម្រង់ផ្សេងៗ ដែលបានរកឃើញពីកន្លែងជាច្រើន នៃអរិយធម៌នេះរួមមានរូបចម្លាក់ត្រា គ្រឿងស្មូនដី គ្រឿងអលង្ការ រូបចម្លាក់ដី អំពីថ្ម លោហៈធាតុ និងអំពីដីឥដ្ឋជាដើម។ ឧទា.រូបចម្លាក់ល្បីៗ

[៥] https://whc.unesco.org: Archaeological Ruins at Mohenjo-Daro

[៦] https://www.khanacademy.org:Indus River Valley civilization

មួយចំនួនដូចជា រូបចម្លាក់ស្ដេច Priest ធ្វើអំពីថ្ម ដែលបានរកឃើញនៅ Mohenjo-daro និង រូបស្ត្រីរបាំធ្វើអំពីសំរិទ្ធ ជាដើម (រូបលេខ៨-៩)។

នៅឆ្នាំប្រមាណ ១៧០០មុនគ.ស. ទីក្រុងនៃអរិយធម៌ឥណ្ឌូសត្រូវបានគេបោះបង់ចោល។[៧] អ្នកស្រាវជ្រាវជឿថាការបោះបង់នេះគឺ ប្រហែលមុនឆ្នាំ១៧០០ទៅទៀតបណ្ដាលមកពីកត្តាជាច្រើនដែលធ្វើឱ្យអរិយធម៌មួយនេះធ្លាក់ចុះ ពោលមានដូចជាការបញ្ចប់ពាណិជ្ជកម្មជាមួយមេសូប៉ូតាមី និងអេហ្ស៊ីប កត្តាសង្គ្រាម និងជាពិសេសកត្តាធម្មជាតិដែលទឹកទន្លេឥណ្ឌូស និងទន្លេ Ghaggar-Hakra រីងស្ងួតដែលធ្វើឱ្យខ្វះប្រភពទឹកក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។[៨]

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

[៧] https://www.bbc.co.uk: What happened to the Indus civilisation?

[៨] *Ibid*




រូបលេខ១៖ ផែនទីនៃអរិយធម៌ឥណ្ឌូស

ប្រភព៖ https://www.khanacademy.org



រូបលេខ២៖ ទីក្រុង Mohenjo-daro

ប្រភព៖ Printerest



រូបលេខ៣៖ ទីក្រុង Harappa

ប្រភព៖ https://whc.unesco.org

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៤៖ ទីក្រុង Mohenjo-daro ថតពីខាងលើ

ប្រភព៖ Pinterest



រូបលេខ២៥៖ អណ្តូងទឹកនៅក្នុងក្រុង Mohenjo-daro

ប្រភព៖ https://whc.unesco.org

អត្ថបទដោយ៖ អេង តុលា



រូបលេខ៦៖ រូបត្រាដែលមានចម្លាក់ និងអក្សរ

ប្រភព៖ https://www.khanacademy.org



រូបលេខ៧៖ រូបចម្លាក់អទិទេពបង្កកំណើត

(Mother Goddess) រក្សាទុកនៅសារមន្ទីរ New Delhi

ប្រភព៖ Museum National of India

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៨៖ រូបចម្លាក់ស្តេច Priest រក្សាទុក នៅសារមន្ទីរ Karachi

ប្រភព៖ https://www.khanacademy.org



រូបលេខ២៩៖ រូបចម្លាក់ស្ត្រីរបាំរក្សាទុកនៅ សារមន្ទីរ New-Delhi

ប្រភព៖ https://www.khanacademy.org

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង

Brisset Isabelle.

2014. La spécialisation du travail artisanal dans la civilisation de l’Indus

www.dailymail.co.uk: Indus Valley civilization
https://www.britannica.com: Mahejo-daro
https://whc.unesco.org: Archaeological Ruins at Mohenjo-Daro
https://www.khanacademy.org:Indus River Valley civilization

https://www.bbc.co.uk: What happened to the Indus civilization?

អត្ថបទដោយ៖ អេង តុលា